ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២១០/១៦ - ប្រេគ្គត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេងថុង**

## ~~ភាគីនៃវិវាទ~~

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ប្រេគ្គត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត**

អាសយដ្ឋាន ៖ ភូមិលេខ៤ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ ៖ គ្មាន ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖ គ្មាន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**

- **សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន ប្រេគ្គត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត**

អាសយដ្ឋាន ៖ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥០៤ ១៥៤ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក ស៊ាង យ៉ូត ប្រធានលេខាធិការដ្ឋានវិវាទនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

| | |
|---|---|
| ២- កញ្ញា ទេព ភារ៉ូ | មន្ត្រីច្បាប់នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣- លោក ស៊ឹម សំអូន | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ៤- លោក នៅ វត្ថា | សកម្មជនសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ៥- លោកស្រី ស៊ុន ស្រីម៉ាច | សកម្មជនសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ៦- លោកស្រី គីម គីមអៃ | សកម្មជនសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ៧- លោកស្រី សុន សារឿន | សកម្មជនសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ៨- លោក ថន កុសល | សកម្មជនសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ៩- លោកស្រី គ្រុយ មករា | សកម្មជនសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ១០- លោក អេង សារឿន | សកម្មជនសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ១១- លោកស្រី ទ្រី សុខនីម | លេខាធិការសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ១២- លោកស្រី អ៊ុន សុខរិទ្ធ | ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ថេកស្តាយ ហ្វេកធើរី លីមីធីត |
| ១៣- លោកស្រី សូត្រ សុភឿន | កម្មករ |
| ១៤- លោកស្រី ប៉ូ សុធា | កម្មករ |
| ១៥- កញ្ញា ថៅ ហ៊ួ | កម្មករ |
| ១៦- លោកស្រី រីង ពៅ | កម្មករ |
| ១៧- លោកស្រី នៅ ចរិយា | កម្មករ |
| ១៨- លោក ឈិត បុប្ផា | កម្មករ |

១៩- កញ្ញា នីម សាអែម កម្មករ

២០- លោកស្រី នៅ ស្រីលា កម្មករ

២១- លោកស្រី ភិន ចន្ថា កម្មករ

២២- លោកស្រី កែប សេង កម្មករ

២៣- លោកស្រី ឈានសៀកណេត កម្មករ

២៤- លោក សា រឿន កម្មករ

២៥- លោកស្រី ពែក ស្រីម៉ៅ កម្មករ

២៦- លោកស្រី ហុង រីម កម្មករ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករទាមទារនិយោជកទូរទាត់ប្រាក់បំណាច់កិច្ចសន្យាផ្សេងៗ តាមច្បាប់ ជូនបុគ្គលិក កម្មករនិយោជិត ដូចខាងក្រោម ៖

ក- ប្រាក់ជូសការជូនដំណឹងមុន (មាត្រា ៧៥)

ខ- ប្រាក់បំណាច់បណ្តេញចេញ (មាត្រា ៨៩)

គ- ប្រាក់សោហ៊ុយជំងឺចិត្ត (មាត្រា ៩១)

ឃ- ប្រាក់ជូសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (មាត្រា ១៦៦)

ង- ប្រាក់ឈ្នួលចុងក្រោយ និងអត្ថប្រយោជន៍ផ្សេងៗ ដែលមិនទាន់បើក (មាត្រា ១៦៦)

២- ទាមទារនិយោជកបើកប្រាក់រំលឹក ជូនឈ្មោះ ជា រឿន អត្តលេខ AB ២៥៧៦ ដែលមានតួនាទីជាសកម្មជនសហជីព នឹងជាប្រតិភូបុគ្គលិកឱ្យបានគ្រប់ចំនួន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២២ កប/ប្រក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ (អាណត្តិទី១៤)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្រ្គេត អនធើរ ផើតស្តាយ ឃោកចើរ លីមីធីត

លេខ ១៥៣១/១៦ ក.ប/កណ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក )។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ និងធ្វើការផ្សះផ្សាវិវាទ ចំនួន ០២ ចំណុចនេះ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាដែលនៅសល់ទាំង ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គ្រេត អនន៌រ ផេកស្កាយ ហ្វេកធើរី លីមីធីត លេខ ១៥៣/១៦ ក.ប/កណ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៦។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំង ០២ ចំណុច នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីកម្មករនិយោជិត មានវត្តមាននៅក្នុងសវនាការតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំណែកឯភាគីនិយោជកមិនបានចូលរួមសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ១៤ និង ៣០ នាទី រសៀល មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានយកលិខិតអញ្ជើញឱ្យភាគីនិយោជកជ្រើសរើសអាជ្ញាកណ្តាល ទៅដល់ទីតាំងក្រុមហ៊ុន ប៉ុន្តែមិនបានជួបជាមួយនឹងនិយោជកនោះទេ ពីព្រោះនៅក្រុមហ៊ុនមានតែវត្តមានមន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, មន្ត្រីតុលាការ, អាជ្ញាធរមានសមត្ថកិច្ច និងកម្មករនិយោជិត ដែលបានលើកឡើងថា និយោជកបានរត់បាត់ហើយ ហើយតុលាការកំពុងចុះអនុវត្តដីការក្សាការពារ។ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជកអំពីសវនាការ ដោយផ្ញើលិខិតអញ្ជើញតាមរយៈប្រៃសណីយ៍កម្ពុជា ដោយមានភ្ជាប់លិខិតអញ្ជើញ លេខ ១១៣៣ កប/អក/វក/ លកអ. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ និងមានបញ្ជាក់ពីអាសយដ្ឋាន ព្រមទាំងកាលបរិច្ឆេទច្បាស់លាស់ ដើម្បីឱ្យនិយោជកចូលរួមសវនាការសំណុំរឿងនេះ

២១០/១៦ នេះ។ ដោយឡែក ភ្នាក់ងារប្រៃសណីយ៍បានយកលិខិតអញ្ជើញនេះត្រឡប់មកវិញ និងបានបញ្ជាក់ថា ក្រុមហ៊ុននេះបានផ្អាកដំណើរការហើយ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ០២ ចំណុចនេះបន្ថែមទៀត ដោយភាគីកម្មករនិយោជិតបានសម្រេចដកចំណុចវិវាទទី២ ចេញពីសំណុំរឿងនេះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាចំណុចវិវាទដែលនៅសល់ ចំនួន ០១ ចំណុចប៉ុណ្ណោះ គឺ ចំណុចវិវាទទី១។

សេចក្តីបង្គាប់នៅក្នុងសំណុំរឿងនេះ ជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតលេខ ២០១/១៦.វិវាទ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចាត់តាំងលោក ស៊ាង យ៉ូត ជាមន្ត្រីដោះស្រាយវិវាទ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីសម្របសម្រួលលើករណីវិវាទក្រុមហ៊ុន ហ្វ្រេគ អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត។

២- ភស្តុតាងគាំទ្រលើចំណុចមិនសះជាទី២។

៣- លិខិតលេខ ១៩៣៥/១៥ កប/កណ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល គោរពជូន នាយកក្រុមហ៊ុន ហ្វ្រេគ អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត ស្តីពីការបញ្ឈប់កម្មករឈ្មោះ ជា រឿន អត្តលេខAb ២៥៧៦ ផ្នែកតម្បាញ និងចង់ត និងជាប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ហ្វ្រេគ អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត។

៤- លិខិតលេខ ១៩៣៥/១៥ ក.ប/ក.ណ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល គោរពជូនលោក ជា រឿន កម្មករក្រុមហ៊ុនហ្វ្រេគអនទើរ (ប្រតិភូ)។

៥- ភស្តុតាងគាំទ្រលើចំណុចមិនសះជាទី១។

៦- ពាក្យបណ្តឹង និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ របស់ថ្នាក់ដឹកនាំសហជីពតំណាងឱ្យសមាជិក ប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន Great Honor Textile Factory Limited គោរពជូន ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីការពឹងពាក់ និងផ្ទេរសិទ្ធិដោះស្រាយនូវលក្ខខណ្ឌការងារមួយចំនួន នៅក្រុមហ៊ុន Great Honor Textile Factory Limited ។

៧- បញ្ជីវត្តមានប្រជុំដាក់ពាក្យបណ្តឹង ករណីក្រុមហ៊ុន ហ្រេត អនន័រ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ទីកន្លែង ស៊ីខៅខ្ញូ ។

៨- កំណត់ហេតុស្តីពីក្រុមហ៊ុន ហ្រេត អនន័រ មិនបើកប្រាក់ខែ ប្រចាំខែកក្កដា ឆ្នាំ២០១៦ ជូនបងប្អូនកម្មករនិយោជិត ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ។

៩- បញ្ជីវត្តមានអ្នកចូលរួមប្រជុំ នៅក្រុមហ៊ុន ហ្រេត អនន័រ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦ ។

១០- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃរោងចក្រ វ៉ិនណើ បានចុះបញ្ជិកា លេខ ១១៧៧ ក.ប/វក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ។

១១- លិខិតលេខ ៥១៩ ក.ប/អក/វក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២៩១៥ របស់នាយកដ្ឋានវិវាទការងារជម្រាបមក លោកប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃរោងចក្រ ហ្រេត អនន័រ ថេកស្ទាយ ហ្វេកធើរី លីមីតធីត ស្តីពីការស្នើទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២ ។

១២- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ហ្រេត អនន័រ ថេកស្ទាយ ហ្វេកធើរី លីមីតធីត លេខ ០៥៧/១៥ ក.ប/វ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ។

១៣- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ របស់សមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន ហ្រេត អនន័រ គោរពជូន ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីផ្ទេរសិទ្ធិជូនលោកប្រធានជួយដោះស្រាយវិវាទការងារ ករណីក្រុមហ៊ុនមិនបើកប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗ ។

១៤- ពាក្យបណ្តឹង និងលិខិតផ្ទេរសិទ្ធិរបស់កម្មករនិយោជិត មិនមែនជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន ហ្រេត អនន័រ គោរពជូន ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីផ្ទេរសិទ្ធិជូនលោកប្រធានជួយដោះស្រាយវិវាទការងារ ករណីក្រុមហ៊ុនមិនបើកប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ។

១៥- បញ្ជីរាយនាមសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ហ្រេត អនន័រ ថេកស្ទាយ ហ្វេកធើរី លីមីតធីត ចំនួន ៧២០ នាក់ ។

THE ARBITRATION COUNCIL

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្វ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត ១៥៣១/១៦ ក.ប/កណ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្វ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិតលេខ ១១០២ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក នាយកក្រុមហ៊ុន ហ្វ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសអាជ្ញាកណ្តាល ពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសមាគមនិយោជក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១១៣៣ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១១៣៤ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ហ្វ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត តទៅនេះឱ្យហៅថា “ក្រុមហ៊ុន ហ្វ្រេត អនទើរ” គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បង ផ្នែកតម្បាញ។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតចំនួនប្រហែល ៩៨២ នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្វ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត)*។
- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ វ៉ីនណឹ (បច្ចុប្បន្នប្តូរឈ្មោះជាក្រុមហ៊ុន ហ្វ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត) ទទួលបានវិញ្ញាបនបត្រចុះបញ្ជិកាសហជីព លេខ ១១៧៧ ក.ប/វក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ និងមានលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ហ្វ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត លេខ ៥១៩ ក.ប/អក/វក ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ រួមមាន ៖ លោក អ៊ិន សុខវិទ្ធ

ជាប្រធាន, លោក ស៊ឹម សំអួន ជាអនុប្រធាន និងកញ្ញា ទ្រី សុខនីម ជាលេខាធិការិនី។ សហជីពនេះជាសហជីពដែលមានភាពជាតំណាងបំផុតប្រចាំរោងចក្រ ហ្វ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត ដោយមានវិញ្ញាបនបត្របញ្ជាក់ភាពជាតំណាងបំផុត លេខ ០៩៧/១៥ ក.ប/វ.ប ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ និងត្រូវមានសុពលភាពត្រឹមថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧។

- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ឱ្យក្រុមអាជ្ញាកណ្តាលធ្វើការដោះស្រាយវិវាទការងាររួមនេះ ជូនកម្មករនិយោជិត ដែលមានបញ្ជាក់អត្តសញ្ញាណច្បាស់លាស់ ដូចដែលមាននៅក្នុងឯកសារដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។
- នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ភាគីកម្មករនិយោជិតបានដាក់ឯកសារបញ្ជីរាយនាមសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ចំនួន ៧២០ នាក់ (មានភ្ជាប់ក្នុងឧបសម្ព័ន្ធ)។
- នៅថ្ងៃសវនាការកម្មករនិយោជិត ចំនួន ២៤ នាក់ ដែលជាថ្នាក់ដឹកនាំសហជីព និងសមាជិកសហជីពមានវត្តមានក្នុងសវនាការ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិតទាំង ២៤ នាក់នោះ ក៏មានឈ្មោះនៅក្នុងឯកសារខាងលើនោះផងដែរ។

ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទូទាត់ប្រាក់បំណាច់កិច្ចសន្យាផ្សេងៗ តាមច្បាប់ ជូនកម្មករនិយោជិត ដូចជា ៖ ក. ប្រាក់ជូសការជូនដំណឹងមុន (មាត្រា ៧៥), ខ. ប្រាក់បំណាច់បណ្តេញចេញ (មាត្រា ៨៩), គ. ប្រាក់សោហ៊ុយជម្ងឺចិត្ត, ឃ. ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (មាត្រា ១៦៦) និងប្រាក់ឈ្នួលចុងក្រោយ និងអត្ថប្រយោជន៍ផ្សេងៗ ដែលមិនទាន់បើក (មាត្រា ១១៦)

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកទូទាត់ប្រាក់បំណាច់បំណាច់ផ្តាច់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ រួមមាន ៖ ១)ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន, ២)ប្រាក់បំណាច់បណ្តេញចេញ, ៣) ប្រាក់សោហ៊ុយជម្ងឺចិត្ត ដែលស្មើនឹងប្រាក់បំណាច់បណ្តេញចេញ, ៤)ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ និង ៥)ប្រាក់ឈ្នួលចុងក្រោយ សម្រាប់ខែកក្កដា ឆ្នាំ២០១៦ និងប្រាក់ឈ្នួល ចំនួន ០៦ ថ្ងៃទៀត គិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦ ជូនកម្មករនិយោជិត ចំនួន ៧២០នាក់។
- ភាគីកម្មករនិយោជិតបានអះអាងថា កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន សុទ្ធតែមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ជាមួយនិយោជក ហើយកម្មករនិយោជិតទាំងអស់ សុទ្ធតែមានអតីតភាពការងារចាប់ពី ១០ ឆ្នាំ ទៅ ១៨ ឆ្នាំ។
- ភាគីកម្មករនិយោជិតបានអះអាងថា និយោជកបានផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦។ មូលហេតុដែលកម្មករនិយោជិតអាចបញ្ជាក់ពីការផ្តាច់កិច្ចសន្យាការងារនេះ គឺដោយសារ នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦ ដែលជាថ្ងៃបើកប្រាក់ឈ្នួលសម្រាប់ខែកក្កដា ឆ្នាំ២០១៦ កម្មករនិយោជិតបានទៅធ្វើការជាធម្មតានាពេលព្រឹក ហើយនិយោជកបានប្រាប់ទៅ

កម្មករនិយោជិតថា នឹងបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតនៅម៉ោង ៣ រសៀល ថ្ងៃនោះ។ បន្ថែមពីនេះទៅទៀត និយោជកបានឱ្យកម្មករនិយោជិតឈប់សម្រាកមួយរសៀលនៅថ្ងៃដដែល ដោយបើកប្រាក់ឈ្នួលឱ្យ ចំនួន ៥០ ភាគរយ ព្រោះតែក្រុមហ៊ុនមិនមានការងារសម្រាប់ឱ្យកម្មករនិយោជិតធ្វើ។ ដោយឡែក នៅពេលរសៀល និយោជកមិនបាននៅក្រុមហ៊ុនទេ ហើយបានគេចខ្លួនបាត់ ដោយមិនទាន់បានបើកប្រាក់ឈ្នួលខែកក្កដា ឆ្នាំ២០១៦ ដល់កម្មករនិយោជិតនៅឡើយ។

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា និយោជកត្រូវទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារជូនកម្មករនិយោជិតទាំង ៧២០ នាក់ខាងលើ ស្របតាមច្បាប់ស្ដីពីការងារ ដូចខាងក្រោម ៖
    - ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន ព្រោះថា ករណីនេះ ជាការរំលាយកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ដោយមិនមានការជូនដំណឹងមុនស្របតាមមាត្រា ៧៥ នៃច្បាប់ស្ដីពីការងារ ហើយក៏មិនមែនបណ្ដាលមកពីករណីប្រធានសក្ដិនោះដែរ។
    - ប្រាក់បំណាច់បណ្ដេញចេញ ស្របតាមមាត្រា ៨៩ នៃច្បាប់ស្ដីពីការងារ ពីព្រោះ កិច្ចសន្យាការងាររបស់កម្មករនិយោជិត គឺជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។
    - ប្រាក់សោហ៊ុយជម្ងឺចិត្ត ស្មើនឹងប្រាក់បំណាច់បណ្ដេញចេញ ស្របតាមមាត្រា ៩១ នៃច្បាប់ស្ដីពីការងារ ពីព្រោះ ការផ្ដាច់កិច្ចសន្យានេះ មិនបានធ្វើឡើងដោយមានហេតុផលសមរម្យនោះទេ។
    - ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ ស្របតាមមាត្រា ១៦៦ នៃច្បាប់ស្ដីពីការងារ ដែលភាគីកម្មករនិយោជិតធ្វើការអះអាងថា មានចំនួន ១៩ ថ្ងៃ សម្រាប់កម្មករនិយោជិតទាំងអស់ ដោយហេតុថា ពួកគាត់បានប្រើប្រាស់អស់ ចំនួន ០២ ថ្ងៃតែប៉ុណ្ណោះ និង
    - ប្រាក់ឈ្នួលចុងក្រោយ ប្រចាំខែកក្កដា ឆ្នាំ២០១៦ និងរយៈពេល ០៦ ថ្ងៃទៀត គិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦ ស្របតាមមាត្រា ១១៦ នៃច្បាប់ស្ដីពីការងារ ដោយហេតុថា និយោជកមិនទាន់បានបើកឱ្យកម្មករនិយោជិត។

**ហេតុផលនៃសេចក្ដីសម្រេច ÷**

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបកស្រាយអំពីនីតិវិធីអាជ្ញាកណ្ដាល នៅពេលអវត្តមានភាគីនិយោជក និងអំពីសិទ្ធិតំណាងជាមុនសិន ៖

**ក. អវត្តមានរបស់ភាគីនិយោជក**

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ។ ហេតុនេះ មុននឹងធ្វើការពិចារណាលើចំណុចវិវាទ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចធ្វើសវនាការ ដោយអវត្តមានរបស់ភាគីនិយោជក ដែរ ឬទេ?

ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញា*

*កណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះ អវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ ។ "* ។

ទាក់ទងនឹងខ្លឹមសារនៃប្រការ ២១ នៃប្រកាសលេខ ០៩៩ ខាងលើនេះ នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ នៅពេលដែលភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវ តែបែរជាខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការរបស់ខ្លួន ដោយធ្វើការបើកសវនាការកំបាំងមុខភាគីដែលអវត្តមាននោះ ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥៣/០៤-គួងហុង, លេខ ១៤៨/០៧-ប៉ាយ ហឺ, លេខ ៩៩/០៩-យឹង ឡែន, លេខ ១៧៣/១១-ជិន អ៊ីង, លេខ ១៤២/១២-អប្សរា, លេខ ១០៩/១៣-វិទ្យាស្ថាន ប៊ុណ្ណា កម្ពុជា, លេខ ១៦៣/១៤-ស៊ីន ឆាង ស៊ីង ហ្គាមេន (ខេមបូឌា), លេខ ៣៣៣/១៥-យ៉ាន ដា រ៉ុង ហ្វុង (ខេមបូឌា) ថេកស្ទាយ, លេខ ១២១/១៦-វ៉ាំឡុង (ខេមបូឌា) អៅសូល អ៊ិនដាស្ទ្រី អិលធីឌី និងលេខ ១៣៤/១៦-គីន តាយ ហ្គាមេន ខូអិលធីឌី*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។

នៅក្នុងសំណុំរឿងនេះ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ១៤ និង ៣០ នាទី រសៀល មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានយកលិខិតអញ្ជើញឱ្យភាគីនិយោជកជ្រើសរើសអាជ្ញាកណ្តាលទៅដល់ទីតាំងក្រុមហ៊ុន ប៉ុន្តែ មិនបានជួបជាមួយនឹងនិយោជកនោះទេ ពីព្រោះ នៅក្រុមហ៊ុនមានតែវត្តមានមន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, មន្ត្រីតុលាការ, អាជ្ញាធរមានសមត្ថកិច្ច និងកម្មករនិយោជិត ដែលបានលើកឡើងថានិយោជកបានរត់បាត់ហើយ ហើយតុលាការកំពុងចុះអនុវត្តដីការក្សាការពារ ។ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជកតាមរយៈប្រៃសណីយ៍កម្ពុជា ដោយមានភ្ជាប់លិខិតអញ្ជើញ លេខ ១១៣៣ កប/អក/វក/ លកអ. ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ និងមានបញ្ជាក់ពីអាសយដ្ឋាន ព្រមទាំងកាលបរិច្ឆេទច្បាស់លាស់ ដើម្បីឱ្យនិយោជកចូលរួមសវនាការសំណុំរឿងលេខ ២១០/១៦ នេះ ។ ដោយឡែក ភ្នាក់ងារប្រៃសណីយ៍បានយកលិខិតអញ្ជើញនេះត្រឡប់មកវិញ និងបានបញ្ជាក់ថា ក្រុមហ៊ុននេះបានផ្អាកដំណើរការហើយ ។

យោងតាមប្រការ ២១ នៃប្រកាសលេខ ០៩៩ និងតាមរយៈការរៀបរាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានប្រើប្រាស់គ្រប់មធ្យោបាយរួចហើយ ដើម្បីអញ្ជើញភាគីនិយោជកមកចូលរួមសវនាការ ប៉ុន្តែ ភាគីនិយោជកមិនមានវត្តមាននៅក្នុងសវនាការ ដោយមិនបានទទួលព័ត៌មានអំពីហេតុផលសមរម្យណាមួយក្នុងការមិនចូលរួមសវនាការនោះទេ ។

ដូច្នេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបន្តដំណើរការរបស់ខ្លួន ដោយធ្វើការធ្វើសវនាការកំបាំងមុខភាគីនិយោជក និងចំពោះមុខភាគីកម្មករនិយោជិត ដើម្បីវិនិច្ឆ័យលើសំណុំរឿង ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ដោយផ្អែកលើភស្តុតាង និងការបកស្រាយបំភ្លឺរបស់ភាគីកម្មករនិយោជិតនៅក្នុងសវនាការ ។

THE ARBITRATION COUNCIL

**ខ. សិទ្ធិតំណាង**

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។"* ។

នៅក្នុងសំណុំរឿងលេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើ ថា ៖ *"...មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម. ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលអាចធ្វើជាតំណាងឱ្យកម្មករនិយោជិតដើម្បីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។"* ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៧១/១៦-ជេវើលីន ខូអិលធីឌី, លេខ ១៧៩/១៦-ដាលី ហ្គាម៉ិន អ៊ិនធើណេសិនណល (ខេមបូឌា) លីមីតធីត, លេខ ១៨៣/១៦-យីដា មេនូហ្វេកឆឺរើ ខូអិលធីឌី, លេខ ១៨៨/១៦-ប្រ៊ីន សាំមីត (ខេមបូឌា) លីមីធីត, និងលេខ ១៩១/១៦-អ៊ីខូ បេស ហ្វេកធើរី)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ហ្វ្រេត អនន័រ ថេកស្តាយ ហ្វេកធើរី លីមីធីត ជាសហជីពមានភាពជាតំណាងបំផុត ប្រចាំរោងចក្រ ហ្វ្រេត អនន័រ ថេកស្តាយ ហ្វេកធើរី លីមីធីត ដោយមានវិញ្ញាបនបត្របញ្ជាក់ភាពជាតំណាងបំផុត លេខ ០៥៧/១៥ ក.ប/វ.ប ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ និងត្រូវមានសុពលភាពត្រឹមថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧។ម្យ៉ាងទៀត នៅថ្ងៃសវនាការថ្នាក់ដឹកនាំសហជីពនេះ ក៏មានវត្តមានក្នុងសវនាការផងដែរ។

យោងតាមការបកស្រាយខ្លឹមសារនៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ហ្វ្រេត អនន័រ ថេកស្តាយ ហ្វេកធើរី លីមីធីត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យកម្មករនិយោជិតទាំងអស់ ដើម្បីនាំយកវិវាទការងាររួម ក្នុងការដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជក ទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់រួមមាន ១) ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន, ២) ប្រាក់បំណាច់បណ្តេញចេញ, ៣) ប្រាក់សោហ៊ុយជម្ងឺចិត្ត ដែលស្មើនឹងប្រាក់បំណាច់បណ្តេញចេញ, ៤) ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ និង ៥) ប្រាក់ឈ្នួលចុងក្រោយ សម្រាប់ខែកក្កដា**

ឆ្នាំ២០១៦ និងសម្រាប់រយៈពេល ០៦ ថ្ងៃទៀត គិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦ ជូនកម្មករនិយោជិត ចំនួន ៧២០ នាក់

**ក. តើនិយោជកផ្ដាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៧២០ នាក់ ខាងលើ នៅពេលណា?**

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបានអះអាងថា និយោជកបានផ្ដាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦។

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតបានលើកឡើងថា នៅរសៀល ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦ ដែលជាថ្ងៃបើកប្រាក់ឈ្នួល កម្មករនិយោជិតបានទៅធ្វើការជាធម្មតានាពេលព្រឹក ហើយនិយោជកបានប្រាប់ទៅកម្មករនិយោជិតថា នឹងបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតនៅពេលថ្ងៃ។ បន្ថែមពីនេះទៅទៀត និយោជកបានឱ្យកម្មករនិយោជិតឈប់សម្រាកមួយរសៀលនៅថ្ងៃដដែល ដោយបើកប្រាក់ឈ្នួលឱ្យ ចំនួន ៥០ ភាគរយ ព្រោះតែក្រុមហ៊ុនមិនមានការងារសម្រាប់ឱ្យកម្មករនិយោជិតធ្វើ។ ដោយឡែក នៅពេលរសៀល និយោជកមិនបាននៅក្រុមហ៊ុនទេ ហើយបានគេចខ្លួនបាត់ ដោយមិនទាន់បានបើកប្រាក់ឈ្នួលខែកក្កដា ឆ្នាំ២០១៦ ដល់កម្មករនិយោជិតនៅឡើយ។ ហេតុនេះ ភាគីកម្មករនិយោជិតអះអាងថា និយោជកបានផ្ដាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦។

ភាគីនិយោជកបានបោះបង់សិទ្ធិរបស់ខ្លួន ក្នុងការឆ្លើយតបនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ទាក់ទងទៅនឹងការលើកឡើងរបស់ភាគីកម្មករនិយោជិត ដោយមិនបានចូលរួមសវនាការអាជ្ញាកណ្ដាលតាមការអញ្ជើញ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចទទួលស្គាល់ការលើកឡើងរបស់ភាគីកម្មករនិយោជិត ដែលថា និយោជកបានផ្ដាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៦។

**ខ. តើនិយោជកមានកាតព្វកិច្ចក្នុងការទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារទាំង ០៥ ចំណុចខាងលើ ជូនកម្មករ និយោជិត ចំនួន ៧២០ នាក់ ដែលធ្វើការទាមទារក្នុងសំណុំរឿងនេះ ដែរ ឬទេ?**

នៅក្នុងសវនាការ កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន សុទ្ធតែមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ជាមួយនិយោជក។

មាត្រា ៧៤ នៃច្បាប់ស្ដីពីការងារ ចែងថា ៖ "*កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន។ ការរំលាយកិច្ចសន្យានេះ ត្រូវអនុវត្តទៅតាមរបៀបឱ្យដំណឹងមុន ជាលាយលក្ខណ៍អក្សរ ដែលភាគីមានបំណងចង់រំលាយកិច្ចសន្យាត្រូវឱ្យទៅភាគីម្ខាងទៀត។*

*ក៏ប៉ុន្តែ គ្មានការបញ្ឈប់ណាមួយអាចធ្វើទៅបាន ដោយគ្មានហេតុផលសមរម្យ ទាក់ទងនឹងសម្បទា ឬចរិយា នៃកម្មករនិយោជិត យោងទៅលើភាពចាំបាច់នៃដំណើរការសហគ្រាស របស់គ្រឹះស្ថាន ឬរបស់ក្រុមហ៊ុនឡើយ។*" ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងលេខ ០២៩/១៥-ប្រ៊ីធីស អីមើវិខិន ធ្វីមើកខូ ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៧ បានបកស្រាយថា ៖ "*... ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីនិយោជកមានសិទ្ធិរំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតដោយឆន្ទៈខ្លួនឯងបាន ដោយផ្ដល់ដំណឹងដល់កម្មករនិយោជិត ដោយបញ្ជាក់ពីហេតុផលសមរម្យ ទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោងទៅលើភាពចាំបាច់*

*នៃដំណើររបស់សហគ្រាសរបស់គ្រឹះស្ថាន ឬរបស់ក្រុមហ៊ុន ។"* ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥១/០៨-អេអេសឌី ហេតុផលនៃចំណុចវិវាទទី៣, លេខ១៦០/១៣-អង្គការអន្តរជាតិបម្រើសុខភាពប្រជាជនកម្ពុជា (PSI) ហេតុផលនៃចំណុចវិវាទទី០១, លេខ ១៦៣/១៤-ស៊ីន ឆាង ស៊ឹង ហ្គាមេន (ខេមបូឌា) ហេតុផលនៃចំណុចវិវាទ, លេខ ១៧៨/១៤-សួនឧស្សាហកម្ម មេនហាតធេន ហេតុផលនៃចំណុចវិវាទទី១, លេខ ១៧៣/១៥-សុកហ្វីន ខេស៊ីឌី ហេតុផលនៃចំណុចវិវាទទី០១, លេខ ០៩៦/១៦-តាក សាន់ អេនធើប្រាយ (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី២ និងទី១២, លេខ ០៩៨/១៦-គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត ហេតុផលនៃចំណុចវិវាទទី០១ និងលេខ ១១៥/១៦-ស្រាបៀរ កម្ពុជា ខេមប្រ៊ូវ ហេតុផលនៃចំណុចវិវាទទី២) ។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនបានបញ្ជាក់ពីហេតុផលសេចក្តីរម្យណាមួយទាក់ទងនឹងសម្បទា ឬ ចរិយានៃកម្មករនិយោជិតទាំង ៧២០ នាក់ខាងលើ យោងទៅលើភាពចាំបាច់នៃដំណើររបស់ក្រុមហ៊ុន ក្នុងការផ្តាច់កិច្ចសន្យាការងាររបស់ពួកគាត់ ស្របតាមមាត្រា ៧៤ នៃច្បាប់ស្តីពីការងារនោះទេ ហើយក៏មិនមានការរើរៀបចំផ្ទៃក្នុងនៃគ្រឹះស្ថានឡើយ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាអំពីប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ទាំង ៧២០ នាក់ តាមប្រភេទកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ដូចខាងក្រោម ៖

១- ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន ៖

មាត្រា ៧៥ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"ថិរវេលាដែលត្រូវឱ្យដំណឹងមុន ត្រូវកំណត់ជាអប្បបរមាដូចតទៅ ៖*

- *ដប់ប្រាំថ្ងៃ បើកម្មករនិយោជិតបានធ្វើការជាប់ក្នុងសហគ្រាសពីប្រាំមួយខែ រហូតដល់ពីរឆ្នាំ ។*
- *មួយខែ បើកម្មករនិយោជិតបានធ្វើការជាប់ក្នុងសហគ្រាសលើសពីពីរឆ្នាំរហូត ដល់ប្រាំឆ្នាំ ។*
- *ពីរខែ បើកម្មករនិយោជិតបានធ្វើការជាប់ក្នុងសហគ្រាសលើសពីប្រាំឆ្នាំ រហូតដល់ដប់ឆ្នាំ ។... ។"* ។

មាត្រា ៧៧ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈនៃនិយោជកតែឯកឯងគ្មានឱ្យដំណឹងមុន ឬមិនគោរពតាមរយៈពេលនៃការឱ្យដំណឹងមុន តំរូវឱ្យនិយោជកចេញប្រាក់ទូទាត់ដល់កម្មករនិយោជិត មានចំនួនស្មើគ្នានឹងប្រាក់ឈ្នួល ហើយនិងអត្ថប្រយោជន៍គ្រប់ប្រភេទដែលកម្មករនិយោជិតត្រូវបាន ក្នុងរយៈពេលឱ្យដំណឹងមុន ដែលគេមិនបានគោរពត្រឹមត្រូវ ។"* ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកមិនបានជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យាការងារ តាមអតីតភាពការងាររបស់កម្មករនិយោជិត ទាំង ៧២០ នាក់ខាងលើ ស្របតាមមាត្រា ៧៥ នៃច្បាប់ស្តីពីការងារនោះទេ ។

ហេតុនេះ កម្មករនិយោជិតទាំង ៧២០ នាក់ខាងលើ មានសិទ្ធិទទួលបានប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលនៃចំនួនថ្ងៃ ដែលនិយោជកត្រូវជូនដំណឹងតាមអតីតភាពរបស់ពួកគាត់ យោងតាមមាត្រា ៧៥ និង ៧៧ នៃច្បាប់ស្តីពីការងារនេះ ។

ការគណនាប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥១/០៤-សាំហាន់ ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ *"...និយោជកត្រូវផ្តល់ប្រាក់ដែលមិនបានជូនដំណឹងនេះ ទៅកម្មករនិយោជិត ចំនួន ១ ខែ ប៉ុណ្ណោះ ។ ប្រាក់ដែលត្រូវផ្តល់ជូន ១ ខែនេះ គឺជាប្រាក់ខែជាមធ្យមភាគប្រចាំខែ ដែលត្រូវគិតដោយឈរលើមូលដ្ឋាន ដូចតទៅ ៖ ប្រាក់ឈ្នួលសរុបទាំងអស់ដែលរួមទាំងប្រាក់ការងារបន្ថែមម៉ោង និងប្រាក់រង្វាន់ដែលកម្មករនោះទទួលបានក្នុងរយៈពេល ១២ ខែ មុនពេលបណ្តេញចេញ ចែកនឹង១២ គឺជាប្រាក់ខែជាមធ្យមភាគប្រចាំខែ ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ត្រូវផ្អែកទៅតាមមធ្យមភាគប្រាក់ឈ្នួលដែលបានទទួលក្នុងរយៈពេល ១២ ខែ ចុងក្រោយ ។

២-ប្រាក់បំណាច់បណ្តេញចេញ ៖

មាត្រា ៨៩ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"ប្រសិនបើកិច្ចសន្យាការងារត្រូវបញ្ឈប់ដោយឆន្ទៈ របស់និយោជកតែម្ខាង វៀរលែងតែក្នុងករណីដែលកម្មករនិយោជិតមានកំហុសធ្ងន់ និយោជកត្រូវតែឱ្យទៅកម្មករនិយោជិតដែលខ្លួនបញ្ឈប់ ... នូវប្រាក់បំណាច់បណ្តេញចេញដែលមានកំរិត ដូចតទៅ ៖*

- *ចិរវេលាធ្វើការលើសពីដប់ពីរខែទៅ ប្រាក់បំណាច់បណ្តេញចេញត្រូវគណនា ស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ចំនួនដប់ប្រាំថ្ងៃ ក្នុងមួយឆ្នាំការងារ ។ ប្រាក់បំណាច់បណ្តេញចេញអតិបរមា មិនអាចលើសប្រាក់ឈ្នួល និង ប្រាក់ បន្ទាប់បន្សំប្រាំមួយខែទេ ។ បើចិរវេលាធ្វើការលើសពីមួយឆ្នាំ ហើយមានប្រភាគចិរវេលាធ្វើការចាប់ពីប្រាំមួយខែឡើង ត្រូវគិតស្មើនឹងមួយឆ្នាំពេញ ។"* ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបញ្ឈប់កម្មករនិយោជិតទាំង ៧២០ នាក់ខាងលើ ពីការងារ គឺមិនផ្អែកលើកំហុសធ្ងន់នោះទេ ។ ហេតុនេះ យោងតាមមាត្រា ៨៩ នៃច្បាប់ស្តីពីការងារ ពួកគាត់មានសិទ្ធិទទួលបានប្រាក់បំណាច់បណ្តេញចេញ ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ចំនួន ១៥ ថ្ងៃ ក្នុងមួយឆ្នាំការងារ ប៉ុន្តែ ប្រាក់បំណាច់បណ្តេញចេញអតិបរមា មិនអាចលើសប្រាក់ឈ្នួល និង ប្រាក់បន្ទាប់បន្សំប្រាំមួយខែទេ ។

ការគណនាប្រាក់បំណាច់បណ្តេញចេញ

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៥១/០៤-សាំហាន់ ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ *"ក្នុងការសម្រេចអំពីរបៀបគណនាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ តាមគោលបំណងមាត្រា ៨៩ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានណែនាំដោយមាត្រា ១៦៨ ដែលតម្រូវឱ្យការ*

THE ARBITRATION COUNCIL

*គណនាប្រាក់ក្នុងអំឡុងពេលឈប់សំរាក ដោយផ្អែកលើមូលដ្ឋានប្រាក់ដែលរកបាន ជាមធ្យមក្នុងរយៈពេល ១២ ខែ ។ ឧទាហរណ៍ កម្មករម្នាក់ដែលមានអតីតភាពការងារ ១៣ ខែ មានសិទ្ធិទទួលបានប្រាក់ឈ្នួល និងផលប្រយោជន៍បន្ទាប់បន្សំ ចំនួន ១៥ ថ្ងៃ ដោយយោងតាមច្បាប់មាត្រា ៨៩ ត្រូវបានគណនា ដូចខាងក្រោម ៖*

*ប្រាក់ឈ្នួលសរុបទាំងអស់ដែលរួមទាំងប្រាក់ការងារបន្ថែមម៉ោង និងប្រាក់រង្វាន់ដែលកម្មករនោះ ទទួលបានក្នុងរយៈពេល ១២ ខែ មុនពេលបណ្តេញចេញ ចែកនឹង ១២ គឺជាប្រាក់ខែជាមធ្យមភាគប្រចាំខែ ។ ប្រាក់ខែជាមធ្យមភាគប្រចាំខែ ចែកនឹង ២៦ គឺជាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ។ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃនេះ គឺជាមូលដ្ឋាននៃការគិតប្រាក់បំណាច់បណ្តេញចេញ ។" ។ (សូមមើលបន្ថែមនៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលសំណុំរឿងលេខ ២៧/០៤-អឹមអេស អាយ ហេតុផលនៃចំណុចវិវាទទី១) ។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ត្រូវផ្អែកទៅតាមមធ្យមភាគប្រាក់ឈ្នួលដែលបានទទួលក្នុងរយៈពេល ១២ ខែ ចុងក្រោយ ។

**៣- សោហ៊ុយជម្ងឺចិត្ត ៖**

មាត្រា ៩១ នៃច្បាប់ការងារ ចែងថា ៖ "*ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈផ្ទាល់នៃភាគីមួយ ដោយគ្មានហេតុផលត្រឹមត្រូវនោះ អាចបើកសិទ្ធិឱ្យភាគីម្ខាងទៀតទារសងសោហ៊ុយជំងឺចិត្តបាន ។ សោហ៊ុយជំងឺចិត្តនេះ មិនត្រូវច្រឡំជាមួយនឹងប្រាក់បំណាច់ទូទាត់ជួសការឱ្យដំណឹងមុន ឬជាមួយនឹងប្រាក់បំណាច់បណ្តេញចេញទេ ។ កម្មករនិយោជិត អាចទាមទារប្រាក់បំណាច់បើកផ្តាច់មួយ ដែលមានចំនួនស្មើនឹងប្រាក់បំណាច់បណ្តេញចេញ ។ ក្នុងករណីនេះ កម្មករនិយោជិតត្រូវបានរួចពីកាតព្វកិច្ចដែលត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីការខូចខាតរបស់ខ្លួន ។*" ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនបានបង្ហាញហេតុផលត្រឹមត្រូវ ក្នុងការផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៧២០ នាក់ខាងលើនោះទេ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពួកគាត់មានសិទ្ធិទទួលបានសោហ៊ុយជម្ងឺចិត្ត ដែលមានចំនួនស្មើនឹងប្រាក់បំណាច់បណ្តេញចេញ ។

**៤- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ៖**

មាត្រា ១៦៦ កថាខ័ណ្ឌទី ១ និងទី២ នៃច្បាប់ស្តីពីការងារ ចែងថា ៖ " *លើកលែងតែមានបញ្ញត្តិ ក្នុងអនុសញ្ញារួម ឬកិច្ចសន្យាការងាររៀងខ្លួន ដែលផ្តល់អត្ថប្រយោជន៍ច្រើនជាងនោះ កម្មករនិយោជិតទាំងអស់ត្រូវមានសិទ្ធិឈប់សំរាក ប្រចាំឆ្នាំមានប្រាក់ឈ្នួល ដែលនិយោជកត្រូវចេញឱ្យ ។ ឯថ្ងៃឈប់សំរាកនេះ ត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះ ក្នុងរយៈពេលធ្វើការមួយខែជាប់ ។....*" ។

មាត្រា ១៦៧ នៃច្បាប់ស្តីពីការងារ ចែងថា ៖ "*ទាល់តែធ្វើការមកបានគ្រប់មួយឆ្នាំ ទើបអាចមានសិទ្ធិឈប់សំរាក ។*

THE ARBITRATION COUNCIL

*ក្នុងករណីដែលមានផ្តាច់ ឬចប់កិច្ចសន្យាមុន ដែលកម្មករនិយោជិតទទួលសិទ្ធិបានឈប់សំរាកនោះ ត្រូវសង ប្រាក់បំណាច់ទៅកម្មករនិយោជិតនោះតាមកំរិតក្នុងមាត្រា ១៦៦ ខាងលើ ។... ។*" ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ៧២០ នាក់ខាងលើ មានសិទ្ធិទទួលបានប្រាក់បំណាច់ទូទាត់ជូសការឈប់សម្រាកប្រចាំឆ្នាំ ដែលមិនទាន់បានប្រើប្រាស់អស់មុនពេលបញ្ចប់កិច្ចសន្យាស្របតាមមាត្រា ១៦៦ និងមាត្រា ១៦៧ នៃច្បាប់ស្តីពីការងារនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវបើកប្រាក់បំណាច់ទូទាត់ជូសការឈប់សម្រាកប្រចាំឆ្នាំ ដែលមិនទាន់បានប្រើប្រាស់អស់មុនពេលបញ្ចប់កិច្ចសន្យា ទៅតាមចំនួនថ្ងៃនៃការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ជូនកម្មករនិយោជិតទាំង ៧២០ នាក់ខាងលើ ក្នុងករណីដែលនិយោជកមិនទាន់បើកប្រាក់នេះជូនពួកគាត់។

<u>ការគណនាប្រាក់បំណាច់ទូទាត់ជូសការឈប់សម្រាកប្រចាំឆ្នាំ</u>

មាត្រា ១៦៨ នៃច្បាប់ស្តីពីការងារ ចែងថា ៖ "*និយោជកត្រូវបង់ឱ្យកម្មករនិយោជិតទៅពេលមុនថ្ងៃឈប់សំរាក នូវប្រាក់វិភាជន៍ យ៉ាងហោចណាស់ស្មើនឹងចំនួនមធ្យមនៃប្រាក់ឈ្នួល បុព្វលាភ វិភាជន៍ អត្ថប្រយោជន៍បំណាច់ គិតទាំងតំលៃវត្ថុដែលផ្តល់ឱ្យផង ដោយមិនគិតពីបំណាច់សងសោហ៊ុយដែលកម្មករនិយោជិតបានបើករួចមកហើយ ក្នុងរយៈពេលដប់ពីរខែមុនថ្ងៃឈប់សំរាក។ ប្រាក់វិភាជន៍នេះ ក្នុងករណីណាក៏ដោយមិនត្រូវឱ្យតិចជាងវិភាជន៍ដែលកម្មករនិយោជិតត្រូវបើកកាលបើខ្លួនបានធ្វើការដោយទៀងទាត់នោះឡើយ ។*" ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រា ១៦៨ នៃច្បាប់ស្តីពីការងារនេះថា ៖ "*និយោជកត្រូវធ្វើការគណនាប្រាក់ឈ្នួលក្នុងអំឡុងពេលឈប់សម្រាកប្រចាំឆ្នាំ ដោយយកប្រាក់ឈ្នួលសរុបនៃរយៈពេលដប់ពីរខែចុងក្រោយ ដែលកម្មករនិយោជិតធ្វើបានមកចែកនឹងដប់ពីរ ដើម្បីរកប្រាក់មធ្យមក្នុងមួយខែ។ បន្ទាប់មកយកប្រាក់ឈ្នួលមធ្យមក្នុងមួយខែនេះ មកចែកនឹង ២៦ ដើម្បីរកប្រាក់ឈ្នួលមធ្យមក្នុងមួយថ្ងៃ ដើម្បីប្រើជាប្រាក់ឈ្នួល ធ្វើជាមូលដ្ឋានសម្រាប់បង់ឱ្យកម្មករនិយោជិតក្នុងពេលឈប់សម្រាកប្រចាំឆ្នាំ ។*" ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៧/០៨-អ៊ីមវើ១ ហេតុផលនៃចំណុចវិវាទទី៧ និង លេខ ២៥/០៨-អេអេសឌី ហេតុផលនៃចំណុចវិវាទទី២*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងខាងលើដែរ ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ត្រូវផ្អែកទៅតាមមធ្យមភាគប្រាក់ឈ្នួលដែលបានទទួលក្នុង រយៈពេល ១២ ខែ ចុងក្រោយ ។

៥- ប្រាក់ឈ្នួលចុងក្រោយ ៖

មាត្រា ១១៦ នៃច្បាប់ស្តីពីការងារ ចែងថា ៖ "*...ក្នុងករណីរំលាយកិច្ចសន្យាការងារ ប្រាក់ឈ្នួល និង ប្រាក់បំណាច់គ្រប់ប្រភេទ ត្រូវបើកក្នុងរយៈពេលសែសិបប្រាំបីម៉ោង បន្ទាប់ពីថ្ងៃឈប់ធ្វើការ ។*" ។

THE ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ៧២០ នាក់ខាងលើ មានសិទ្ធិទទួលបានប្រាក់ឈ្នួលចុងក្រោយ រហូតដល់កាលបរិច្ឆេទធ្វើការចុងក្រោយរបស់ពួកគាត់។ ហេតុនេះ និយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលចុងក្រោយ ជូនពួកគាត់ ក្នុងករណីដែលនិយោជកមិនទាន់បើកប្រាក់នេះជូនពួកគាត់។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារ ជូនកម្មករនិយោជិត ទាំង ៧២០ នាក់ខាងលើ តាមការគណនា ដូចខាងក្រោម ៖

១. ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន តាមមាត្រា ៧៥ និងមាត្រា ៧៧ នៃច្បាប់ស្តីពីការងារ។

២. ប្រាក់បំណាច់បណ្តេញចេញ តាមមាត្រា ៨៩ នៃច្បាប់ស្តីពីការងារ។

៣. ប្រាក់សោហ៊ុយជម្ងឺចិត្ត តាមមាត្រា ៩១ នៃច្បាប់ស្តីពីការងារ។

៤. ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ តាមមាត្រា ១៦៦ និងមាត្រា ១៦៧ នៃច្បាប់ស្តីពីការងារ ក្នុងករណីមិនទាន់បានផ្តល់ជូនពួកគាត់។

៥. ប្រាក់ឈ្នួលចុងក្រោយ តាមមាត្រា ១១៦ នៃច្បាប់ស្តីពីការងារ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

បង្គាប់ឱ្យនិយោជកទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារ ជូនកម្មករនិយោជិត ទាំង ៧២០ នាក់ (សូមមើលឧបសម្ព័ន្ធ) តាមការគណនា ដូចខាងក្រោម ៖

១. ប្រាក់បំណាច់ទូទាត់ជួសការជូនដំណឹងមុន តាមមាត្រា ៧៥ និង ៧៧ នៃច្បាប់ស្តីពីការងារ។

២. ប្រាក់បំណាច់បណ្តេញចេញ តាមមាត្រា ៨៩ នៃច្បាប់ស្តីពីការងារ។

៣. ប្រាក់សោហ៊ុយជម្ងឺចិត្ត តាមមាត្រា ៩១ នៃច្បាប់ស្តីពីការងារ។

៤. ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ តាមមាត្រា ១៦៦ និងមាត្រា ១៦៧ នៃច្បាប់ ស្តីពីការងារ ក្នុងករណីមិនទាន់បានផ្តល់ជូនពួកគាត់។

៥. ប្រាក់ឈ្នួលចុងក្រោយ តាមមាត្រា ១១៦ នៃច្បាប់ស្តីពីការងារ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា ៖ ---------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ីន គីមស៊ាន**

ហត្ថលេខា ៖---------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **អាំង អេងថុង**

ហត្ថលេខា ៖ ---------------------------------------

## បញ្ជីរាយនាមសមាជិកសហជីព

## ប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រហ្គោតអនឌើរ ថេកស្តាយ ហ្វេកធើរី លីមីតធីត

| ល.រ | ឈ្មោះ | ភេទ | អត្តលេខ | ក្រុម | ផ្នែក | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ជិន ចិន្តា | ស្រី | E.0004 | | ប៉ះពិនិត្យ | |
| ២ | ពេញ ស្រីនូ | ស្រី | E.0005 | | ប៉ះពិនិត្យ | |
| ៣ | អ៊ិន ផាក់ | ស្រី | E.0015 | | ប៉ះពិនិត្យ | |
| ៤ | អាត គន្ធា | ស្រី | E.0018 | | ប៉ះពិនិត្យ | |
| ៥ | សេង សុភក្តី | ស្រី | E.0023 | | ប៉ះពិនិត្យ | |
| ៦ | ពេញ វាសនា | ស្រី | E.0024 | | ប៉ះពិនិត្យ | |
| ៧ | ស្រេង ឡុន | ស្រី | E.0027 | | ប៉ះពិនិត្យ | |
| ៨ | ស៊ុម ធារី | ស្រី | E.0032 | | ប៉ះពិនិត្យ | |
| ៩ | ផូ សាមី | ស្រី | E.0033 | | ប៉ះពិនិត្យ | |
| ១០ | អូន ស្រីធំ | ស្រី | E.0034 | | ប៉ះពិនិត្យ | |
| ១១ | លន់ សុភ័ណ្ឌ | ស្រី | E.0037 | | ប៉ះពិនិត្យ | |
| ១២ | ប៉ន ចាន់ឌី | ស្រី | E.0039 | | ប៉ះពិនិត្យ | |
| ១៣ | ទិត្យ សេដ្ឋា | ស្រី | E.0041 | | ប៉ះពិនិត្យ | |
| ១៤ | ឃុន សុភាព | ស្រី | E.0046 | | ប៉ះពិនិត្យ | |
| ១៥ | ជួប ស្រីនាង | ស្រី | E.0047 | | ប៉ះពិនិត្យ | |
| ១៦ | សឿន ស្រីពៅ | ស្រី | E.0049 | | ប៉ះពិនិត្យ | |
| ១៧ | វ៉ាន់ ដេ្ធា | ស្រី | E.0052 | | ប៉ះពិនិត្យ | |
| ១៨ | ឆន រត្តនា | ស្រី | E.0053 | | ប៉ះពិនិត្យ | |
| ១៩ | សៃ វ៉ាន់ឌី | ស្រី | E.0052 | | ប៉ះពិនិត្យ | |
| ២០ | ជិន ស៊ីថា | ស្រី | E.0055 | | ប៉ះពិនិត្យ | |
| ២១ | សេត សុខនី | ស្រី | E.0057 | | ប៉ះពិនិត្យ | |
| ២២ | លន់ មួយគា | ស្រី | E.0061 | | ប៉ះពិនិត្យ | |
| ២៣ | ជុំ សុវ៉ែន | ស្រី | E.0064 | | ប៉ះពិនិត្យ | |
| ២៤ | ប៊ុច ស្រីរឿន | ស្រី | E.0070 | | ប៉ះពិនិត្យ | |
| ២៥ | មុត ឈុន | ស្រី | E.0072 | | ប៉ះពិនិត្យ | |
| ២៦ | នឿន ស៊ីថា | ស្រី | E.0074 | | ប៉ះពិនិត្យ | |
| ២៧ | ផាន់ សុខណា | ស្រី | E.0075 | | ប៉ះពិនិត្យ | |
| ២៨ | ហ៊ុល ហាក់ | ស្រី | E.0076 | | ប៉ះពិនិត្យ | |
| ២៩ | ឌឹម សារ៉េម | ស្រី | E.0077 | | ប៉ះពិនិត្យ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣០ | ស្រ៊ូ លាងស្រ៊ី | ស្រី | E.0078 | | ប៉ះពិនិត្យ | |
| ៣១ | ពេញ ចិន្តា | ស្រី | E.0081 | | ប៉ះពិនិត្យ | |
| ៣២ | ម៉ៅ ស្រីទូច | ស្រី | E.0082 | | ប៉ះពិនិត្យ | |
| ៣៣ | ស៊ុន គីមស៊ | ស្រី | E.0084 | | ប៉ះពិនិត្យ | |
| ៣៤ | ចំរើន សុភា | ស្រី | E.0086 | | ប៉ះពិនិត្យ | |
| ៣៥ | អូន ស្រីម៉ៅ | ស្រី | E.0088 | | ប៉ះពិនិត្យ | |
| ៣៦ | ស៊ិន ស៊ីចាន់ | ស្រី | E.0092 | | ប៉ះពិនិត្យ | |
| ៣៧ | អ៊ុល សុខខៃ | ស្រី | E.0096 | | ប៉ះពិនិត្យ | |
| ៣៨ | យឹម ចរិយា | ស្រី | E.0097 | | ប៉ះពិនិត្យ | |
| ៣៩ | ប៉ាច សុភា | ស្រី | E.0100 | | ប៉ះពិនិត្យ | |
| ៤០ | ខេត្ត ស៊ីណា | ស្រី | E.0101 | | ប៉ះពិនិត្យ | |
| ៤១ | អឿន ស្រីអន | ស្រី | E.0102 | | ប៉ះពិនិត្យ | |
| ៤២ | គ្រុយ ស្រីមុំ | ស្រី | E.0109 | | ប៉ះពិនិត្យ | |
| ៤៣ | គ្រុយ ស្រីម៉ិច | ស្រី | E.0110 | | ប៉ះពិនិត្យ | |
| ៤៤ | គ្រុយ សុខជឹម | ស្រី | E.0112 | | ប៉ះពិនិត្យ | |
| ៤៥ | សុង ណារិន | ស្រី | E.0120 | | ប៉ះពិនិត្យ | |
| ៤៦ | ចិន វាសនា | ស្រី | E.0122 | | ប៉ះពិនិត្យ | |
| ៤៧ | កែវ ស្រី | ស្រី | E.0123 | | ប៉ះពិនិត្យ | |
| ៤៨ | យឿន ស៊ីណាង | ស្រី | E.0125 | | ប៉ះពិនិត្យ | |
| ៤៩ | អៀម ផល្លី | ស្រី | E.0130 | | ប៉ះពិនិត្យ | |
| ៥០ | មីន សុខគីម | ស្រី | E.0131 | | ប៉ះពិនិត្យ | |
| ៥១ | ម៉ុន វន្ទី | ស្រី | E.0135 | | ប៉ះពិនិត្យ | |
| ៥២ | លន់ ផែត | ស្រី | E.0142 | | ប៉ះពិនិត្យ | |
| ៥៣ | អ៊ិន ស្រីមុំ | ស្រី | E.0147 | | ប៉ះពិនិត្យ | |
| ៥៤ | ឃ្លី គីមយ៉ាន | ស្រី | E.0160 | | ប៉ះពិនិត្យ | |
| ៥៥ | អ៊ឹង ស្រីតូច | ស្រី | E.0162 | | ប៉ះពិនិត្យ | |
| ៥៦ | ចាន់ ម៉ារី | ស្រី | E.0165 | | ប៉ះពិនិត្យ | |
| ៥៧ | ជឹម ជឿន | ស្រី | E.0168 | | ប៉ះពិនិត្យ | |
| ៥៨ | សុខ សុផានី | ស្រី | E.0170 | | ប៉ះពិនិត្យ | |
| ៥៩ | ហ៊ឹម ពៅ | ស្រី | E.0171 | | ប៉ះពិនិត្យ | |
| ៦០ | ភី សុភាព | ស្រី | E.0172 | | ប៉ះពិនិត្យ | |
| ៦១ | លី សុភាព | ស្រី | E.0173 | | ប៉ះពិនិត្យ | |

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

| | | | | | | |
|---|---|---|---|---|---|---|
| ៦២ | ផល យុន | ស្រី | E.0275 | | ប៉ះពិនិត្យ | |
| ៦៣ | ឡុយ ចន្ទី | ស្រី | E.0285 | | ប៉ះពិនិត្យ | |
| ៦៤ | ចាប ចាន់ឡឿន | ស្រី | E.0286 | | ប៉ះពិនិត្យ | |
| ៦៥ | ជឹម សុភី | ស្រី | E.0292 | | ប៉ះពិនិត្យ | |
| ៦៦ | យឿន សាបូ | ស្រី | E.0293 | | ប៉ះពិនិត្យ | |
| ៦៧ | យ៉ុន សុខៃ | ស្រី | E.0296 | | ប៉ះពិនិត្យ | |
| ៦៨ | ម៉េត ណៃស្រ៊ាន់ | ស្រី | E.0299 | | ប៉ះពិនិត្យ | |
| ៦៩ | ម៉ៅ សារុន | ស្រី | E.0303 | | ប៉ះពិនិត្យ | |
| ៧០ | ប៉េន ឈី | ស្រី | E.0304 | | ប៉ះពិនិត្យ | |
| ៧១ | កែវ សុភី | ស្រី | E.0310 | | ប៉ះពិនិត្យ | |
| ៧២ | ហេង ដាលីន | ស្រី | E.0311 | | ប៉ះពិនិត្យ | |
| ៧៣ | ព្រំ ខេន | ស្រី | E.0314 | | ប៉ះពិនិត្យ | |
| ៧៤ | ឯក សុវណ្ណី | ស្រី | E.0315 | | ប៉ះពិនិត្យ | |
| ៧៥ | កុក ណាន | ស្រី | E.0317 | | ប៉ះពិនិត្យ | |
| ៧៦ | ឆន ដា | ស្រី | E.0318 | | ប៉ះពិនិត្យ | |
| ៧៧ | ណុច ស៊ីណា | ស្រី | E.0319 | | ប៉ះពិនិត្យ | |
| ៧៨ | ឆៅ ស្រីតូច | ស្រី | E.0323 | | ប៉ះពិនិត្យ | |
| ៧៩ | សួន កឿន | ស្រី | E.0325 | | ប៉ះពិនិត្យ | |
| ៨០ | អ៊ឹម សុខធីម | ស្រី | E.0329 | | ប៉ះពិនិត្យ | |
| ៨១ | រឿន រ៉ុន | ស្រី | E.0330 | | ប៉ះពិនិត្យ | |
| ៨២ | សុង រិទ្ធី | ស្រី | E.0331 | | ប៉ះពិនិត្យ | |
| ៨៣ | ហុង រីម | ស្រី | E.0335 | | ប៉ះពិនិត្យ | |
| ៨៤ | ឃិន មាង | ស្រី | E.0336 | | ប៉ះពិនិត្យ | |
| ៨៥ | ប៉ុង នឿន | ស្រី | E.0340 | | ប៉ះពិនិត្យ | |
| ៨៦ | អួន ស្រីទូច | ស្រី | E.0341 | | ប៉ះពិនិត្យ | |
